**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**KINGDOM OF CAMBODIA**
**Nation - Religion - King**

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce

លេខ ៣៣៣ ព.ណ. ......

ភ្នំពេញ, ថ្ងៃទី ១២ ខែសីហា ឆ្នាំ ២០១១

## សូមគោរពជូន

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
**ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល**
**ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងទេសចរណ៍**
**លោកជំទាវរដ្ឋមន្ត្រី ក្រសួងកិច្ចការនារី**
**ឯកឧត្តមរដ្ឋមន្ត្រី ប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ**
**ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាអគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា**
**ឯកឧត្តមនាយកសាលាភូមិន្ទរដ្ឋបាល**

កម្មវត្ថុ: សំណើសុំចាត់បញ្ជូនមន្ត្រីចូលរួមសិក្ខាសាលាស្តីពី " ការរៀបចំបង្កើតគម្រោងនៃគម្រោងពង្រឹងក្របខ័ណ្ឌសមាហរណកម្មពាណិជ្ជកម្ម Tier 2 សម្រាប់កម្ពុជា " ។

ភ្ជាប់ជូន: បញ្ជីរាយនាមមន្ត្រីអញ្ជើញចូលរួម របៀបវារៈនៃកិច្ចប្រជុំ និង EIF Tier 2 Guideline ។

តបតាមកម្មវត្ថុខាងលើ ខ្ញុំមានកិត្តិយសសូមជម្រាបជូនឯកឧត្តមមេត្តាជ្រាបថា៖ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនៃក្រសួងពាណិជ្ជកម្មនឹងរៀបចំសិក្ខាសាលាមួយស្តីពី "ការរៀបចំបង្កើតគម្រោងនៃគម្រោងពង្រឹងក្របខ័ណ្ឌសមាហរណកម្មពាណិជ្ជកម្ម Tier 2 សម្រាប់កម្ពុជា " ឬ " EIF Tier 2 Project Formulation For Cambodia" ។ គោលបំណងសំខាន់នៃសិក្ខាសាលានេះ គឺដើម្បីកសាងសមត្ថភាពរបស់មន្ត្រីនៃក្រសួង/ស្ថាប័ននីមួយៗដែលពាក់ព័ន្ធឱ្យយល់ដឹងអំពីនីតិវិធី និងគោលការណ៍ណែនាំនានាក្នុងការបង្កើតគម្រោងដោយប្រើប្រាស់ថវិការ Tier 2 របស់ EIF ។

សិក្ខាសាលានេះ នឹងប្រព្រឹត្តទៅនៅ ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១១ វេលាម៉ោង ០៨:30 – ១៧:00 នៅសណ្ឋាគារភ្នំពេញ ក្រោមអធិបតីភាពរបស់ឯកឧត្តម **ប៉ាន សូរស័ក្តិ** រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម និងជា EIF Focal Point ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមមេត្តាចាត់បញ្ជូនមន្ត្រីដែលមានឈ្មោះក្នុងបញ្ជីភ្ជាប់ជូនជាមួយ មកចូលរួមសិក្ខាសាលានេះ កុំបីអាក់ខានឡើយ។

សូមឯកឧត្តម មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ជំនួសរដ្ឋមន្ត្រី**

**ភឹម_ស៊ីថន**

ចម្លងជូន៖
- ខុទ្ទកាល័យឯកឧត្តមទេសរដ្ឋមន្ត្រី
- ឯកឧត្តម ប៉ាន សូរស័ក្តិ
- ឯកឧត្តម សុខ សុភ័ក្ត្រ
- ឯកសារកាលប្បវត្តិ

ឡូត៍លេខ ១៩-៦១ វិថីក្រសួងពាណិជ្ជកម្ម ( ១១៣បេ ), ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ, ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Ministry of Commerce, Lot 19-61, MOC Road (113B Road), Phum Teuk Thla, Sangkat Teuk Thla, Khand Sen Sok, Phnom Penh, Kingdom of CAMBODIA
ទូរស័ព្ទ / ទូរសារ:( ៨៥៥) -២៣ ៨៦៦ ៤៦៩
Phone/Facsimile: (855)-23 866 469